# **សំណួរ ពាក់ព័ន្ធច្បាប់រដ្ឋធម្មនុញ្ញ** (៤)
# **តើរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បាននិយាយអ្វីខ្លះពីគោលការណ៍មិនរើសអើង**

(principle of non-discrimination)?

**<u>ចម្លើយ</u>**

ទង្វើមិនរើសអើងជា អំពើដែលស្មើគ្នា (equal treatment) ឬ ទង្វើប្រព្រឹត្តមិនដូចគ្នា ក៏ប៉ុន្តែ មានហេតុផលសមស្រប។ សកម្មភាពជួយជ្រោងឲ្យមានស្ថានភាពល្អប្រសើរដូចគេឯង ដូចជាសកម្មភាពវិជ្ជមាន (affirmative Action) មិនមែនជាទង្វើរើសអើងទេ (សូមពិនិត្យមើលសំណួរ ចម្លើយពាក់ ព័ន្ធគោលការណ៍បន្ថែមទៀត)។

មាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញ បានចែងដោយផ្អែកនូវគោលការណ៍នេះ៖ *ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់<u>ពូជសាសន៍</u> <u>ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ</u>*។ មាត្រា ៣៦ ចែងបន្ថែម តម្រូវឲ្យមានប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា ការងារមេផ្ទះមានតម្លៃដូចជានឹងកម្រៃនៃការងារធ្វើនៅក្រៅផ្ទះ។ មាត្រា ៤៥ សង្កត់ធ្ងន់ថា គ្រប់ទម្រង់នៃការរើសអើងប្រឆាំង នឹងស្ត្រី ត្រូវលុបបំបាត់។ មាត្រា ៤៦ ចែងមិនឲ្យបញ្ឈប់នារី ដោយសារមូលហេតុមានគភ៌។ ជាចុងក្រោយ ពាក់ព័ន្ធនឹងសកម្មភាពវិជ្ជមាន មាត្រា៤៦ ដដែលចែង៖ *រដ្ឋនិងសង្គមត្រូវផ្តល់ដល់ស្ត្រីជាពិសេសនារីនៅទីជនបទ ដែលគ្មានទីពឹង...ដើម្បី...មានជីវភាពរស់នៅសមរម្យ*។

**<u>កំណត់សំគាល់</u>**៖ មាត្រា ៣១ ប្រើប្រាស់ "*ប្រជាពលរដ្ឋខ្មែរ ...មានសិទ្ធិ...*"។ មាត្រា ១ នៃ អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ៖ *...ពាក្យរើសអើង ...សំដៅដល់ការប្រកាន់ ការបែងចែក ការផាត់ចេញ ឬការរឹតត្បិតផ្អែកលើភេទ ដែលមានអានុភាព ឬមានបំណងធ្វើឲ្យខូចខាត ឬធ្វើមោឃៈភាពនូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់ដោយស្ត្រី ដោយឥតគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រី ផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី នូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងពលរដ្ឋ ឬក្នុងវិស័យដទៃទៀត*។